ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៨៣/២០ នប.ក

# របាយការណ៍ខែមីនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែមេសា ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព ដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្ដីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្ដីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្ដីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្ដីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើ**ការនៅប្រទេសម៉ាឡេស៊ី"។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ១១.៨០៦ លើក | ៦៦៥.៧៤៤ នាក់ |
| ២ | អង្គការដៃគូនានា | ០៤ លើក | ៣៨៩ នាក់ |
| សរុប | | ១១.៨១០ លើក | ៦៦៦.១៣៣ នាក់ |

#### ខ.១.២. វេទិកាសាធារណៈ និងភូមិ ឃុំសុវត្ថិភាព

នៅក្នុងខែមីនា ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១១.៨០៦**លើក មានអ្នកចូលរួមសរុបចំនួន **៦៦៥.៧៤៤**នាក់ (ធៀបនឹងខែកុម្ភៈ មានចំនួន **៥៤១.៤២៦**នាក់ គឺមាន

ការកើនឡើងចំនួន ១២៤.៣១៨នាក់ ស្មើនឹង២២,៩៦% ក្នុងនោះស្ត្រីចំនួន ៣៣៤.៧១២នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

### តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៧៦ | ៣.៩៦២ | ២.៥៦៤ | | | |
| | សរុប ក្រសួង ស្ថាប័ន | ៧៦ លើក | ៣.៩៦២ នាក់ | ២.៥៦៤ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៦២៤ | ៣១.៦១០ | ១៥.១៧៣ | ១.៤២៤ | ៩៥.៤១៤ | ៤៩.២៨៥ |
| ៣ | ខេត្តបាត់ដំបង | ១.៧៥៤ | ៨៦.៦១៣ | ៤៥.៤៥១ | ១.០៣៨ | ២៨.២៩៦ | ១៥.០៨៥ |
| ៤ | ខេត្តពោធិ៍សាត់ | | | | | | |
| ៥ | ខេត្តសៀមរាប | ៥២១ | ៣២.០៦១ | ១៩.៣៧៩ | ១២៤ | ៤.០៩៣ | ២.៣០១ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.១០១ | ៦៣.៨៩៧ | ៣៣.៥៧១ | ៧៣៩ | ២៨.៨៦១ | ១៥.៤០៧ |
| ៧ | ខេត្តកំពង់ចាម | ២.៣៣៩ | ១៦៥.៨៤២ | ៧៤.០១១ | ៤០៤ | ២២.៩៣៨ | ១៣.០៥៤ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៨១ | ២២.០២៦ | ១០.៧៤៩ | ៧០ | ៩.១៤៨ | ១.២៤៧ |
| ១០ | ខេត្តស្វាយរៀង | ៨ | ៣៤ | ២៥ | ៣៥៧ | ១៤.៣៦១ | ៧.៤៧៩ |
| ១១ | ខេត្តប៉ៃលិន | ១២១ | ២.៩៤៨ | ១.៥៨៨ | ៤០ | ២.៦៤១ | ១.២១៦ |
| ១២ | ខេត្តកោះកុង | ៥ | ៥២ | ៤២ | ២៤៤ | ៨.៧២២ | ៤.៨៥១ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ៣២១ | ២០.៣១៨ | ១១.៣៥២ | ១០៣ | ៤.១៤២ | ២.០៩៩ |
| ១៦ | ខេត្តក្រចេះ | ១៤ | ៦៨៦ | ៤២៧ | ៤ | ៦០៦ | ១៣៤ |
| ១៧ | ខេត្តកែប | | | | ១៤ | ២.៨៨៦ | ១.៥៨៦ |
| ១៨ | ខេត្តកំពង់ស្ពឺ | ២៣៥ | ១១.៤២៦ | ៥.៣៨៣ | ៤២ | ១.១៦២ | ៦៦២ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៣ | ៩៩៩ | ៥៩១ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៧.១២៧ លើក | ៤៣៨.៥១២ នាក់ | ២១៧.៧៤២ នាក់ | ៤.៦០៣ លើក | ២២៣.២៧០ នាក់ | ១១៤.៤០៦ នាក់ |

| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ១១.៨០៦ លើក | អ្នកចូលរួមសរុប ៦៦៥.៧៤៤ នាក់ | ស្ត្រីចំនួន ៣៣៤.៧១២ នាក់ |
|---|---|---|---|

### ខ.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

▪ អង្គការដៃគូ

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ របស់អង្គការដៃគូនានា តាមបណ្តាលរាជធានី-ខេត្ត*

| រាជធានី-ខេត្ត | *សកម្មភាព* | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
|---|---|---|---|---|
| ខេត្តបាត់ដំបង អង្គការវីវើល/ជីវីស៊ី | - បានសហការជាមួយក្រុមប្រឹក្សាឃុំ និងភូមិគោលដៅ ក្នុងស្រុកសំឡូត ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងារ របស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់នៃការជួញដូរ មនុស្ស ចំនួន៣ឃុំ។ | ០១ | ១០១ | ៧៦ |
| ខេត្តស្វាយរៀង អង្គការឆាលបហ្វាន អង្គការ CCPCR | - ផ្សព្វផ្សាយអំពីបញ្ហាប្រឈម និងងាយរងគ្រោះដោយការធ្វើចំណាកស្រុក គ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅ ឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុករមាសហែក។ | ០៣ | ១៣៤ | ៧៨ |
| សរុប | | ០៤ លើក | ២៣៥ នាក់ | ១៥៤ នាក់ |

### ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- ខេត្តសៀមរាប៖ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣ MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក ប្រកបដោយសុវត្ថិភាព ពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល និងការ ផ្សព្វផ្សាយអំពីស្គតអប់រំ ស្តីពីគ្រឿងញៀន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងពាក់ព័ន្ធការជួញ ដូរមនុស្ស សរុបចំនួន ៤០លើក (ផ្សាយផ្ទាល់ ១០លើក និងចាក់ផ្សាយឡើងវិញ ៣០លើក)។
- ខេត្តតាកែវ៖ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស តាមរយៈវិទ្យុគោកធ្លក សរុបចំនួន ៣០អត្ថបទ និង ៤២លើក។
- ខេត្តក្រចេះ៖ មន្ទីរព័ត៌មានខេត្តបានផ្សព្វផ្សាយតាមវិទ្យុ ស្តីពីអំពើជួញដូរមនុស្ស ចំនួន ៨៣លើក។
- ខេត្តកំពង់ចាម៖ មន្ទីរព័ត៌មានខេត្តបានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិភ្នំប្រុស ពាក់ព័ន្ធនឹងការធ្វើ ចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០៣លើក រយៈពេល៣ម៉ោង។

### ខ.១.៥. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- ថ្នាក់ជាតិ

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ អគ្គលេខាធិការរង បាន ដឹកនាំក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ទៅធ្វើបទឧទ្ទេសនាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ នៅសាលាហ្វឹកហ្វឺនកងកម្លាំង រក្សាសន្តិភាពពហុជាតិ (PKO) នៅខេត្តកំពង់ស្ពឺ។

- ថ្នាក់ក្រោមជាតិ

- ខេត្តក្រចេះ៖ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារក្រោមប្រធានបទ អំពើហិង្សា និងការរំលោភសេសន្ថវៈលើស្ត្រី និងកុមារ តាមរយៈការផ្សព្វផ្សាយសម្លេង និងការ ផ្សាយផ្ទាល់តាមផេកហ្វេសបុក របស់វិទ្យុសម្លេងស្ត្រីខេត្ត ចំនួន ០១លើក។ R2BT The

### ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

#### ខ.២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣១៩.៥០៦នាក់/៣៣៣.០៩៦នាក់ (ស្រី ១៩១.៦១៣នាក់) អនីតិជន ៥.២៣៨នាក់ (ស្រី ២.០៥៧នាក់) ក្នុងនោះស្របច្បាប់ចំនួន ២១៩.១៤២នាក់/២១២.២២៦នាក់ (ស្រី ១៤២.៩៩៣នាក់) អនីតិជន ៧០១នាក់ (ស្រី ២៧៩នាក់) មិនស្របច្បាប់ ចំនួន ១០០.៣៦៤នាក់/១២០.៨៧០នាក់ (ស្រី ៤៨.៦២០នាក់) អនីតិជន ៤.៥៣៧នាក់ (ស្រី ១.៧៧៨នាក់) បើប្រៀបធៀបនឹងខែមុន គឺមានការថយចុះចំនួន ១៣.៥៩០នាក់ ស្មើនឹង ៤,០៧%។

- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន ៨០លើក ពុំប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។

#### ខ.២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
- ស្នងការដ្ឋាននគរបាលខេត្តតាកែវ កែប ស្វាយរៀង ក្រចេះ ឧត្តរមានជ័យ ត្បូងឃ្មុំ កំពង់ចាម កោះកុង កំពង់ឆ្នាំង និងខេត្តមណ្ឌលគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៦៣០គោលដៅ មានមនុស្សចំនួន ៩.៧១៩នាក់ (ស្រី ៦.០៧៣នាក់)។
- ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ស្វាយរៀង តាកែវ ក្រចេះ កំពង់ស្ពឺ ព្រៃវែង និងខេត្តព្រះវិហារ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៤៧លើក។

#### ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសសរុបចំនួន ១៣៩គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចហើយទៅរស់នៅសាធារណៈរដ្ឋកូរ៉េ ដោយបានទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាម៉ីខ្លួនបានចំនួន ១២នាក់(រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

- ខេត្តកំពង់ចាមៈ

បានបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍ខុសច្បាប់ (ពុំមានលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃ) រវាងឈ្មោះ **RA SEOKHUM** ភេទប្រុស ជនជាតិកូរ៉េ កាន់លិខិតឆ្លងដែនលេខ M08031591 និងឈ្មោះ ចន សុខគង់ ភេទស្រី ជនជាតិខ្មែរ ជាពលការិនីធ្វើការនៅប្រទេសកូរ៉េ។

**២.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- ខេត្តសៀមរាបៈ

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ ស្តីពីការងាររួមមានៈ អធិការកិច្ចសាមញ្ញបានចំនួន ០៧សហគ្រាស និងអធិការកិច្ចក្រៅកម្មវិធីបានចំនួន ០១សហគ្រាស។

- ខេត្តប៉ៃលិនៈ

បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន ចំនួន ៨០កន្លែង។

- ខេត្តកំពង់ស្ពឺៈ

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ ចំនួន ០២លើក (០២ក្រុមហ៊ុន)។

- ខេត្តកោះកុងៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ ចំនួន ០៥លើក។

- ខេត្តតាកែវៈ

មន្ទីរទេសចរណ៍ខេត្ត បានចុះផ្សព្វផ្សាយដល់ម្ចាស់អាជីវកម្ម អំពីការទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ ចំនួន ០២កន្លែង នៅក្រុងដូនកែវ។

- ខេត្តក្រចេះៈ

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌល អង្គការដំណឹងល្អចំនួន ០៤ មានកុមារសរុប ១៧នាក់ (ស្រី ០៥នាក់)។

- **ខេត្តស្វាយរៀងៈ**

អធិការដ្ឋានក្រុងបាវិត បានចុះស្រង់ទិន្នន័យតាមគោលដៅសិប្បកម្ម រោងចក្រ សហគ្រាស ដែលសង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចពលកម្មកុមារ ចំនួន ០៣លើក។

- ខេត្តព្រះវិហារៈ

មានមណ្ឌលថែរក្សាកុមារកំព្រា ចំនួន ០៧ (មណ្ឌលរដ្ឋ ០១ និងមណ្ឌលអង្គការវិហារសាសនា ០៦) មានកុមារសរុប ២០៩នាក់ (ស្រី ៩១នាក់)។

- ខេត្តកែបៈ

មានមណ្ឌលថែរក្សាកុមារកំព្រា ចំនួន ០១កន្លែង កុមារសរុប ៤៧នាក់ (ស្រី ១៧នាក់)។

**២.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ**

- រដ្ឋបាលខេត្តចំនួន០២ គឺខេត្តបាត់ដំបង និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៥.២៦១ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ
    - ខេត្តបាត់ដំបង ចំនួន ៣.៦៣៨ប័ណ្ណ
    - ខេត្តប៉ៃលិន ចំនួន ១.៦២៣ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាន នគរបាលរាជធានី-ខេត្តៈ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កណ្តាល ពោធិ៍សាត់ និងខេត្ត ស្វាយរៀង។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១២ករណី/១១ករណី (ធៀបនឹងខែកុម្ភៈមានការកើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៨នាក់(ស្រី ០៣នាក់) ក្នុងនោះជនសង្ស័យជាអនីតិជនចំនួន ០៣នាក់ និងជនបរទេស ចំនួន ០៥នាក់(សញ្ជាតិស៊ុយអែត ០១នាក់ និងវៀតណាម ០៤នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន ២៨នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៩នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និង អាយុពី១៨ឆ្នាំឡើង ១៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១៧នាក់ និងប្រគល់ឲ្យគ្រួសារ ១១នាក់) ក្នុងនោះមាន បែកជាៈ

##### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៣ករណី លើ០៣ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៤នាក់ (ស្រី ០១នាក់)។ សង្គ្រោះ ជនរងគ្រោះចំនួន ០៤នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៣នាក់ និងអាយុពី១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឲ្យគ្រួសារ ០៤នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ | ០១ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០២ | ស៊ុយអែត១ |
| *សរុប* | *០៣ ករណី* | *០៤ នាក់* | *០៤ នាក់* | *០១ នាក់* |

##### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៩ករណី លើ០៨ករណី (កើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៤នាក់ (ស្រី ០២នាក់) ជាអនីតិជន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២៤នាក់ មានៈ អាយុ១៥-១៧ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុពី១៨ឆ្នាំឡើង ១៥នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ១៧នាក់ និងប្រគល់ឲ្យ គ្រួសារ ០៧នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោស នៃសញ្ជារកម្ម | ០២ | ១៧ | ០៧ | វៀតណាម៤ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ | |

| | | | | |
|---|---|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ<br>-អំពើអាសប្រាតនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥<br>០១ | ០៥<br>០១ | ០៥ (អនី.៣)<br>០១ | |
| *សរុប* | *០៩ករណី* | *២៤ នាក់* | *១៤ នាក់* | *០៤ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  បានជួយអន្តរាគមន៍ឲ្យពលករខ្មែរវិលត្រឡប់មកកម្ពុជាវិញ សរុបចំនួន ១.៩៧៧នាក់ ក្នុងនោះមានៈ ប្រទេសថៃ ចំនួន ១.៩៧១នាក់ និងប្រទេសម៉ាឡេស៊ី ចំនួន ០៦នាក់។
- អគ្គស្នងការដ្ឋាននគរបាលជាតិ
  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ០៤នាក់(ស្រី ០២នាក់) ដែលត្រឡប់ពីប្រទេសម៉ាឡេស៊ី ០២នាក់ ឥណ្ឌូនេស៊ី ០២នាក់។ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ ០២នាក់(ម៉ាឡេស៊ី) និងទៅតាមក្រុមហ៊ុន ០១នាក់ និងទៅដោខ្លួនឯង ០១នាក់(ឥណ្ឌូនេស៊ី)។
- ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
  ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០៥ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ៩៥លើក មនុស្សចំនួន ១.០៩៨នាក់(ស្រី ៣៨៥នាក់ អនីតិជន ៧៩នាក់) ក្នុងនោះមានៈ

| | | | |
|---|---|---|---|
| - ខេត្តបន្ទាយមានជ័យ | ចំនួន ៨៤លើក | មនុស្សចំនួន ៦១១នាក់<br>អនីតិជនចំនួន ៧៤នាក់។ | (ស្រី ១៧២នាក់) |
| - ខេត្តបាត់ដំបង | ចំនួន ០៩លើក | មនុស្សចំនួន ៥១នាក់ | (ស្រី ១៤នាក់)។ |
| - ខេត្តកោះកុង | ចំនួន ០៧លើក | មនុស្សចំនួន ១៦នាក់ | (ស្រី ០៣នាក់)។ |
| - ខេត្តប៉ៃលិន | ចំនួន ០២លើក | មនុស្សចំនួន ៤១៤នាក់<br>អនីតិជនចំនួន ០១នាក់។ | (ស្រី ១៩១នាក់) |
| - ខេត្តស្វាយរៀង | ចំនួន ០១លើក | មនុស្សចំនួន ០៦នាក់<br>អនីតិជន ០៤នាក់។ | (ស្រី ០៥នាក់) |

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ខេត្តកំពង់ឆ្នាំង៖ ស្រុកកំពង់ត្រឡាច បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើផែនការ និងការចុះអប់រំដល់យុវវ័យតាមសហគមន៍ឲ្យចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០១ | ២០ | ១៨ |

| | | | | |
|---|---|---|---|---|
| ២ | **ខេត្តស្វាយរៀង៖** អង្គការឆោលហ្វានកម្ពុជា បានរៀបចំវគ្គរំលឹកឡើងវិញ ដល់អ្នកសម្របសម្រួលមណ្ឌលយុវជន និងជនបង្គោលស្ត្រី និងកុមារ ក្រោមប្រធានបទការស្គាល់ខ្លួនឯង ជំនាញក្នុងការប្រាស្រ័យទាក់ទង និងការគ្រប់គ្រងករណី។ | ០១ | ១២ | ០៨ |
| ៣ | **ខេត្តស្ទឹងត្រែង៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ នៅសាលាខេត្តស្ទឹងត្រែង។ | ០១ | ៧១ | ០ |
| ៤ | **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភីស បានបើកការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តភូមិ មេរៀនទី១ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅ០៥ភូមិគឺ ភូមិថ្មី ភូមិសំបុកអក ភូមិរកា ភូមិតាហែន១ និងភូមិតាហែន២។ | ០៥ | ១០២ | ៦៦ |
| ៥ | **ខេត្តតាកែវ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយអង្គការ ទស្សនៈពិភពលោក បើកវគ្គបណ្តុះបណ្តាល ស្តីពីបណ្តាញការពារកុមារនៅតាមសហគមន៍ នៅឃុំស្លា និងឃុំជំរះពេន ស្រុកសំរោង។ | ០២ | ៦៥ | ៤៥ |
| | សរុប | ១០ វគ្គ | ២៧០ នាក់ | ១៣៧ នាក់ |

## ៦. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ៦.១ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ កិច្ចប្រជុំក្នុងប្រទេស

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖
  - បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយ សារាចរណែនាំ ស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ១៩ របស់ រាជរដ្ឋាភិបាលកម្ពុជា លេខ០១ ស.រ.ណ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០។
  - បានដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ online (video confenence) ជាមួយអង្គការដៃគូអភិវឌ្ឍតំណាង UN ស្តីពីវិធានការឆ្លើយតប បង្ការរីករាលដាលការឆ្លងជម្ងឺកូវីដ១៩ ទៅនឹងការវិលត្រឡប់របស់ពលករទេសន្តរប្រវេសន៍ពីក្រៅប្រទេស។
  - បានដឹកនាំកិច្ចប្រជុំ សម្របសម្រួល និងវាយតម្លៃលើកម្រងសំណួរ រាជធានី-ខេត្ត ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ១៣នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

### ៦.២. ការទទួលជួបពិភាក្សាការងារ

• ថ្នាក់ជាតិ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយលោកស្រី Knistin Parco ជា COM របស់អង្គការ IOM នៅកម្ពុជា ពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

• ថ្នាក់ក្រោមជាតិ

- ខេត្តកោះកុង

លោកស្រីប្រធានមន្ទីរកិច្ចការនារី និងជាអនុប្រធានលេខាធិការដ្ឋានខេត្ត៖ បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា និងតំណាងអង្គការវីនរ៉ក់អន្តរជាតិ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ១៤នាក់ (ស្រី ០៤នាក់)។

- ខេត្តប៉ៃលិន

ឯកឧត្តម ផាន់ ចាន់ធុល អភិបាល នៃគណៈអភិបាលខេត្ត បានជួបពិភាក្សាការងារជាមួយអភិបាលខេត្តច័ន្ទបុរី ប្រទេសថៃ ដើម្បីសម្របសម្រួលដំណើរការចេញ ចូល ទាំងមនុស្ស និងទំនិញ នៅតាមច្រកព្រំដែន។ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍ និងស្ថាប័នពាក់ព័ន្ធ ចុះត្រួតពិនិត្យការវិលត្រឡប់របស់ពលករខ្មែរតាមច្រកព្រំដែនអន្តរជាតិព្រំ និងច្រករបៀង(តាមអូរ តាមព្រៃ...)។

### ខ.៣. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣៦លើក មានអ្នកចូលរួមសរុប ៣.៩៦៦នាក់ (ស្រី ១៨២នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១៧លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៣៦លើក។ **(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ** គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមេសា ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.............ខែ.........ឆ្នាំ ជូត ទោស័ក ព.ស ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.........ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៦លើក) មនុស្សចំនួន ៣.៩៦៦នាក់ (ស្រី ១៨២នាក់)

| **ស្ថាប័នសម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- ក្នុងពិធីអបអរសាទរទិវាអន្តរជាតិ ៨មីនា ខួបលើកទី១០៩ ឆ្នាំ២០២០ ក្រោមប្រធានបទ "**មានសន្តិភាព មានការលើកកម្ពស់សភាពយេនឌ័រ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អ្នកចូលរួមប្រមាណ ៣.០០០នាក់ នៅសាលសន្និបាតកោះពេជ្រ។<br>- ក្នុងពិធីអបអរសាទរទិវាអន្តរជាតិ ៨មីនា ខួបលើកទី១០៩ ឆ្នាំ២០២០ ក្រោមប្រធានបទ "**មានសន្តិភាព មានការលើកកម្ពស់សភាពយេនឌ័រ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អ្នកចូលរួមប្រមាណ ៥០០នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ក្នុងកម្មវិធីសំណេះសំណាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្តីអំពីទិវាអន្តរជាតិនារី ៨មីនា លើកទី១០៩ ឆ្នាំ២០២០ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ក្នុងកម្មវិធីជួបសំណេះសំណាលដោយផ្ទាល់ជាមួយមន្ត្រីនៃអង្គភាពច្រកទ្វារ និងស្ថាប័ននានាដែលកំពុងបំពេញភារកិច្ចតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅខេត្តបន្ទាយមានជ័យ។<br>- បានដឹកនាំក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះទៅច្រកព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាប្រឈមទាក់ទងទៅនឹងការបង្ការ ទប់ស្កាត់ជម្ងឺ COVID.19 ដល់មន្ត្រីរដ្ឋបាលច្រកទ្វារប៉ោយប៉ែត ដែលប្រព្រឹត្តទៅនៅសាលប្រជុំប៉ុស្តិ៍នគរបាលច្រកទ្វារប៉ោយប៉ែត។<br>- បានដឹកនាំក្រុមការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះទៅខេត្តបន្ទាយមានជ័យ ដើម្បីជួបសំណេះសំណាជាមួយពលករខ្មែរដែលបានវិលត្រឡប់ពីប្រទេសថៃវិញ និងបានណែនាំពួកគាត់ឲ្យបានយល់ដឹងអំពីការរីករាលដាលនៃជម្ងឺឆ្លង COVID.19 ។<br>- បានដឹកនាំក្រុមការងារជាស្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមអបអរសាទរខួបលើកទី១០៩ ទិវាជាតិនារី ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ "**មានសន្តិភាព មានការលើកកម្ពស់សភាពយេនឌ័រ**" ដែលមានអ្នកចូលរួមប្រមាណ ១៥០នាក់ នៅខេត្តកំពង់ឆ្នាំង។<br>▪ លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំ ស្តីពី "វិធានការបង្ការ និងទប់ស្កាត់ ការរាតត្បាត នៃជម្ងឺ COVID.19" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំ ឆ្លើយតបទៅនឹងគណៈកម្មាធិការសិទ្ធមនុស្សនៅកម្ពុជា ស្តីពីវឌ្ឍនភាព, សមិទ្ធផល ឧត្តមានុវត្តន៍ និងបញ្ហាប្រឈមទៅតាមវិស័យនីមួយៗ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |

| | |
|---|---|
| | ▪ លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៤ច្បាប់ លិខិតចូល ០៨ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៣ច្បាប់ លិខិតចូល ០៧ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមីនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែមីនា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិគី។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៣៧ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ០៥សកម្មភាព។<br>▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ អគ្គលេខាធិការរង បានអញ្ជើញចូលរួមដឹកនាំក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ប្រជុំពិភាក្សារៀបចំសៀវភៅសិក្សា និងជំនួយវិធីសាស្ត្របង្រៀនអំពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាមួយអង្គការ Caritas និង RATANAK International នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- លោកអនុប្រធានក្រុមបានដឹកនាំមន្ត្រីក្រុមជំនួយកិច្ចការងារបង្ការ ទប់ស្កាត់ ចូលរួមជាមួយក្រុមការងារក្រសួងអប់រំ យុវជន និងកីឡា និងអង្គការដៃគូ ដើម្បីប្រជុំពិភាក្សារៀបចំសៀវភៅការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស(បន្ត) សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលប្រព្រឹត្តទៅនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។<br>- បានប្រជុំពិភាក្សាបន្តជាមួយអង្គការដៃគូពាក់ព័ន្ធ ដើម្បីរៀបចំសៀវភៅសិក្សា និងជំនួយវិធីសាស្ត្របង្រៀន អំពីការង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន០២លើក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ ក្រុមជំនួយកិច្ចការយុត្តិធម៌<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វិរៈ អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីយុទ្ធនាការ "ព័ត៌មានស្អាត" នៅអគារសេរីភាព នៃសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- លោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសដើម្បីពិនិត្យ និងផ្តល់យោបល់លើកម្រងសំណួរការសិក្សាស្រាវជ្រាវស្តីពីការទប់ស្កាត់គ្រោះថ្នាក់ ការកេរប្រវ័ញ្ចផ្លូវភេទលើកុមារ នៅសាលប្រជុំភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- លោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ ស្តីពីការជួញដូរមនុស្ស និងការរំលោភសិទ្ធិពលករទេសន្តរប្រវេសន៍ រៀបចំដោយអង្គការសីលការ និងអង្គការក្រុមការងារស្តីពីសិទ្ធិមនុស្ស (Human Right Working Group) ប្រទេសឥណ្ឌូនេស៊ី ក្រោមការគាំទ្រថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) នៅសណ្ឋាគារ SUN WAY រាជធានីភ្នំពេញ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារខមមីតកម្ពុជា និងក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគ.ជ.ប.ជ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ២០២០ ដើម្បីផ្ញើជូនទៅ គ.ជ.ប.ជ និងរាយការណ៍ពីស្ថានភាពបច្ចុប្បន្ន នៃអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីកំណត់បញ្ហាប្រឈម និងលើកទិសដៅអនុវត្តបន្ត នៅទីស្តីការក្រសួងកិច្ចការនារី។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៩លើក អ្នកចូលរួមសរុបចំនួន ៣១៦នាក់ (ស្រី ១៨២នាក់)** | |
| **ខេត្តកណ្ដាល** | - ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៩លើក អ្នកចូលរួមចំនួន២០៤នាក់ ស្រី១៣៣នាក់។ |
| **ខេត្តសៀមរាប** | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ចំនួន០៣លើក អ្នកចូលរួមចំនួន៧៨នាក់ ស្រី២១នាក់។ |
| **ខេត្តកំពង់ស្ពឺ** | - បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ចំនួន០១លើក នៅមន្ទីរកិច្ចការនារីខេត្ត អ្នកចូលរួមចំនួន៣៤នាក់ ស្រី២៨នាក់។ |
| **ខេត្តកំពង់ឆ្នាំង** | - បានរៀបចំកិច្ចប្រជុំលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមីនា ត្រីមាសទី១ និងលើកទិសដៅការងារអនុវត្តបន្ត។<br>- គ.ខ.ប.ជ បានចុះត្រួតពិនិត្យ និងចាត់វិធានការវេជ្ជសាស្ត្រ ចំពោះពលករចំណាកស្រុកទៅក្រៅប្រទេសដែលត្រឡប់មកស្រុកកំណើតវិញ ចំនួន៥២នាក់។ |
| **ខេត្តតាកែវ** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន០១លើក អ្នកចូលរួមចំនួន៥៨នាក់ ស្រី០៣នាក់។ |
| **ខេត្តកំពង់ចាម** | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការ IOM នៅសណ្ឋាគារ អិល ប៊ី អិន ខេត្តកំពង់ចាម។<br>- បានចូលរួមពិធីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **ខេត្តកោះកុង** | - បានចុះជួបពលករខ្មែរដែលថៃចាប់បញ្ជូនតាមច្រកព្រំដែនអន្តរជាតិចាំយាម ចំនួន០៤នាក់ បានអប់រំណែនាំ និងផ្តល់ថវិកាមួយចំនួន។ |